រាជធានីភ្នំពេញថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០១

# សេចក្តីសំរេចលេខ ១៨ សសរ

## ស្តីពី ការចាត់តាំងគណៈប្រតិភូរាជរដ្ឋាភិបាល
## ទៅធ្វើសវនកម្ម (AUDIT) នៅស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជា
## ប្រចាំទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន

~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសអោយប្រើស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើររបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## សំរេច

**ប្រការ១** : ត្រូវបានចាត់តាំងគណៈប្រតិភូរាជរដ្ឋាភិបាលទៅធ្វើសវនកម្ម (Audit) នៅស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **គង់ វិបុល** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធាន

២- ឯកឧត្តម **ចែម វិឌ្ឍា** អគ្គលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៣- លោកស្រី **ស៊ី ចំនួនទ្ធិ** ប្រធានការិយាល័យគណនេយ្យក្រៅប្រទេស ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

**ប្រការ២** : គណៈប្រតិភូនេះ មានភារកិច្ចដូចតទៅ :

- ស្រាវជ្រាវ និង តាមដានអោយបានច្បាស់នូវចំណូល ចំណាយរបស់ស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅទីក្រុងប៉េកាំង ។
~~~~

- ធ្វើរបាយការណ៍លំអិតជូនរាជរដ្ឋាភិបាលអំពីលិទ្ធផលការងារដែលអនុវត្តបាន និង ស្នើសុំយោបលស់រេចពី រាជរដ្ឋាភិបាលក្នុងករណីមានចាំបាច់ ។

**ប្រការ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្ថានទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងប៉េកាំង និងសមាសភាពដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្ដីសំរេច នេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

---

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០១

## សេចក្ដីសំរេចលេខ១៦ សសរ

## ស្ដីពីការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាលកម្ពុជា

~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១ :** ត្រូវផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្ដីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្ដេចនាយក រដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋកូរ៉េ ចាប់ពីថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០១ រហូតដល់សម្ដេចនាយក រដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

www.pheakdeylaw.com
~~~